# ផ្នែកទី I

# គំនូសសញ្ញាពណ៌សកាត់ទទឹងផ្លូវ

# Transverse Markings

គំនូសសញ្ញាពណ៌ស កាត់ទទឹងផ្លូវ ជាខ្សែគំនូស ដែលជាប់ ឬ ដាច់ៗ ទោល ឬ ភ្លោះ ទៅតាមប្រភេទគំនូសសញ្ញានិមួយៗ ។

គំនូសសញ្ញាប្រភេទនេះ មាននៅកន្លែងជិតចូលផ្លូវប្រសព្វ ឬ រង្វង់មូល ដែលមានផ្លាកសញ្ញា បាត់សិទ្ធិ ដូចជាសញ្ញា **ឈប់** ឬសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេ** សំរាប់កំណត់ទីតាំង អោយអ្នកបើកបរឈប់នៅត្រឹមមុខគំនូសនេះ មុននឹងបន្តដំណើរ ចូលក្នុងផ្លូវធំមានសិទ្ធិអាទិភាព ឬ រង្វង់មូល ។

## ផ្នែកទី I : គំនូសសញ្ញាពណ៌ស កាត់ទទឹងទ្រូងផ្លូវ ( Transverse Markings )



### គំនូសសញ្ញាឈប់ (ទោល)
STOP LINE (SINGLE SOLID)

**លេខកូដ :PW03-M1-01**

**ខ្លឹមសារ :** គំនូសសញ្ញាទោល ជាប់ ពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលបញ្ជាដោយភ្លើងសញ្ញា ចរាចរ ។



### គំនូសសញ្ញាឈប់ (ភ្លោះ)
STOP LINE (DOUBLE SOLID)

**លេខកូដ :PW03-M1-02**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ជាប់ពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលមានផ្លាកសញ្ញា **ឈប់ដើម្បី ផ្តល់សិទ្ធិអាទិភាពអោយគេ** និង គ្មានភ្លើងសញ្ញាចរាចរ ។



### គំនូសសញ្ញាផ្តល់សិទ្ធិអាទិភាព (ភ្លោះ)
GIVE WAY LINE (DOUBLE BROKEN)

**លេខកូដ :PW03-M1-03**

**ខ្លឹមសារ :** គំនូសសញ្ញាភ្លោះ ដាច់ៗពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវប្រសព្វ ដែលមានផ្លាកសញ្ញា **ផ្តល់សិទ្ធិ អាទិភាពអោយគេ** និង គ្មានភ្លើងសញ្ញាចរាចរ ។



### គំនូសសញ្ញាផ្តល់សិទ្ធិអាទិភាព (ទោល)
GIVE WAY LINE (SINGLE BROKEN)

**លេខកូដ :PW03-M1-04**

**ខ្លឹមសារ :** គំនូសសញ្ញាទោល ដាច់ៗពណ៌ស កាត់ទទឹងទ្រូងផ្លូវ ប្រើសំរាប់ កំណត់ទីតាំងអោយអ្នកបើកបរឈប់ នៅត្រឹមមុខគំនូសនេះ នៅត្រង់ផ្លូវចូលរង្វង់មូល ដែលមានផ្លាកសញ្ញា **ផ្តល់សិទ្ធិអាទិភាពអោយគេនៅរង្វង់មូល** ។